**សកម្មភាព** ៖ **ផ្ដុំពណ៌មេរោគ**

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(សិក្សាសង្គម)** ការបង្ហាញពីរសកម្មភាពផ្សេងៗទៀតដែលបានបង្កើតជាស្នាដៃ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "បិសាចចម្លែកតូចៗ" ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ពែងម្សៅពណ៌ ម្សៅពណ៌ ស្លាបព្រាតូច ទុយោរ ក្រដាស និងខ្មៅដៃ កាវ គ្រាប់ភ្នែកជ័រ ឬ កាត់ក្រដាសធ្វើជាគ្រាប់ភ្នែកហើយផាត់ពណ៌។

**ការរៀបចំ** ៖ លាយម្សៅពណ៌ជាមួយទឹកស្តើងៗ ដើម្បីធ្វើឱ្យប្រាកដថាផ្ដុំទៅបើងចេញជារូបរាង។ ត្រូវធ្វើបង្ហាញជាឧទាហរណ៍ដើម្បីបង្ហាញដល់ក្មេងៗទាំងអស់សិន។ ប្រើប្រាស់តាមការណែនាំ និងត្រូវរៀបចំ ចែករំលែកវិធីសាស្រ្តនេះជាមួយក្មេងៗ គូរភ្នែក និងមាត់នៅចំកណ្តាលក្រដាសឱ្យចេញជារូបមេរោគ។ ប្រើស្លាបព្រា ដើម្បីទុកដួសពណ៌ខ្លះៗ ដាក់លើក្រដាសប្រើទុយោរដើម្បីផ្ដុំពណ៌ឱ្យឆ្ងាយពីមុខមេរោគលើក្រដាស ជ្រើសរើសពណ៌ផ្សេងៗទៀត និងធ្វើតាមរហូតទាល់តែអស់នៅលើផ្ទៃក្រដាស ។

**សេក្តីណែនាំ**៖

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**ផ្ដុំពណ៌មេរោគ**ជាមួយកូនៗទាំងអស់គ្នា។
2. នេះជាឧបករណ៍ ពែងម្សៅពណ៌ ម្សៅពណ៌ ស្លាបព្រាតូច ទុយោរ ក្រដាស និងខ្មៅដៃ កាវ គ្រាប់ភ្នែកជ័រ ឬ កាត់ក្រដាសធ្វើជាគ្រាប់ភ្នែកហើយផាត់ពណ៌បិទ។
3. អ្នកគ្រូនឹងបង្ហាញកូនៗពីរបៀប**ផ្ដុំពណ៌មេរោគ**លើក្រដាសឱ្យកូនៗមើលផ្ទាល់។

4. ពន្យល់ក្មេងៗពីរបៀបលេងល្បែងសកម្មភាពមួយហ្នឹង និងធ្វើកាយវិការបង្ហាញ របៀបប្រើទុយោរផ្លុំពណ៌ចេញពីមុខផ្ទាល់កុំឱ្យកកពណ៌ខ្លាំងពេក។
5. ពិភាក្សា៖ តើ ភ្នែក និងមាត់អាចមើលទៅ តូច ធំ ខឹង ញញឹម និងធ្មេញស្រួច-ល-។
6. គូរឧទាហរណ៍. ផ្សេងៗទៀតនៅលើក្តារខៀន និងឱ្យក្មេងៗទាំងអស់ធ្វើវាដែរ ។
7. ចាប់ផ្តើមឱ្យក្មេងៗអនុវត្តផ្ទាល់ ដោយចាប់ផ្តើមចែកសម្ភារដែរ។
8. ចែកក្រដាស ខ្មៅដៃ ពែងពណ៌ និងទុយោរ
9. រំលើកក្មេងថាសំខាន់ជាងគេគឺក្នុងការផ្លុំ ត្រូវប្រយ័ត្ន។
10. ក្រោយការផ្លុំចប់ចាប់ផ្តើមគូរ ភ្នែក មាត់ ច្រមុះ នៅចំកណ្តាលក្រដាស ។
11. ប្រាប់ក្មេងឱ្យលេងដោយសប្បាយរីករាយសម្រាប់ការបង្កើតជាមេរោគខ្លួនឯង។
12. ប្រសិនបើមានពេល ឱ្យពួកគេធ្វើការគូរឱ្យបានច្រើនជាការស្រេច។

**ការប្រែប្រួល៖**

បើមិនមានភ្នែកបិទកាវក៏បាន យើងអាចប្រើខ្មៅដាំគូរជំនួសវិញ។

សម្រាប់មាត់គូរក៏បាន មិនគូរក៏បានតាមចំណង់ចំណូលចិត្ត។

អាចគូរបន្ថែមច្រមុះក៏បាន។



